# ការធានា និងការលើកទឹកចិត្តអ្នកវិនិយោគ

ដោយសារសកម្មភាពវិនិយោគក៏មានគោលដៅស្វែងរកផលចំណេញផ្នែកសេដ្ឋកិច្ច តាមរយៈការបោះទុនវិនិយោគផងដែរនោះ ដូចនេះហានិភ័យណាមួយដែលកើតមានឡើងចំពោះសកម្មភាពវិនិយោគ មុខតែនឹងក្លាយជាឧបសគ្គដល់ការសម្រេចចិត្តបណ្តាក់ទុនវិនិយោគនេះផងដែរ។ ក្នុងគោលដៅទាក់ទាញអ្នកវិនិយោគ រដ្ឋត្រូវតែមានគោលនយោបាយធានា និងលើកទឹកចិត្តដល់ពួកគេ។ ជាទូទៅការធានា និងការលើកទឹកចិត្តនេះ រមែងស្តែងឡើងនៅក្រោមទម្រង់ពីរយ៉ាង៖ តាមរយៈការបង្កើតលិខិតបទដ្ឋានជាតិដើម្បីអនុវត្តទៅលើគ្រប់អ្នកវិនិយោគទាំងអស់នៅលើទឹកដីនៃជាតិនោះ និងតាមរយៈការចុះកិច្ចព្រមព្រៀងទ្វេរ ឬពហុភាគីដើម្បីអនុវត្តតែចំពោះភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងនោះតែប៉ុណ្ណោះ។

## កថាខណ្ឌទី១ កិច្ចធានាវិនិយោគនៅកម្ពុជា

នៅក្នុងក្របខណ្ឌច្បាប់នៃព្រះរាជាណាចក្រកម្ពុជា យើងសង្កេតឃើញមានកិច្ចធានាធំៗមួយចំនួនរួមមាន: ការធានាមិនធ្វើជាតិតូបនីយកម្មរបស់រដ្ឋចំពោះទ្រព្យសម្បត្តិនៃអ្នកវិនិយោគ ដែលធ្វើឡើងដោយច្បាប់ស្តីពីវិនិយោគកម្ពុជាផ្ទាល់តែម្តង និងកិច្ចធានាចំពោះបញ្ហាអស្សាមិករណ៍ដែលអាចនឹងកើតមានជាជាយថាហេតុចំពោះទ្រព្យសម្បត្តិជាអចលនវត្ថុដែលបម្រើដល់សកម្មភាពវិនិយោគរបស់វិនិយោគគិនទាំងឡាយ កាលបើសកម្មភាពវិនិយោគភាគច្រើនតែងមានទំនាក់ទំនងនឹងបញ្ហាដីធ្លី។ ជាចុងក្រោយ គឺជាកិច្ចធានាចំពោះការការពារកម្មសិទ្ធិបញ្ញា ពិសេសគឺការការពារកម្មសិទ្ធិឧស្សាហកម្មដល់អ្នកវិនិយោគទាំងឡាយដូចជាបច្ចេកវិទ្យាជាដើម ហើយរាល់កង្វះខាតនៃកិច្ចធានាក្នុងសម័យកាលបច្ចេកវិទ្យានេះមុខជានឹងពុំអាចទាក់ទាញពួកអ្នកវិនិយោគបានឡើយ។

### ១. ការមិនធ្វើជាតូបនីយកម្មវិនិយោគ

តាមរយៈច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ការមិនធ្វើជាតូបនីយកម្មរបស់រដ្ឋលើផ្នែកណាមួយ ឬទាំងស្រុងនៃទ្រព្យសម្បត្តិរបស់អ្នកវិនិយោគត្រូវបានធានា[1]។ តាមនិយមន័យនៃពាក្យ **ជាតិតូបនីយកម្ម** គឺជាការដកហូតតាមផ្លូវច្បាប់នូវកម្មសិទ្ធិពីម្ចាស់គ្រឹះស្ថាន ឬឧស្សាហកម្មដើម្បីយកដាក់ជាផលប្រយោជន៍របស់ជាតិ [2]។ ប៉ុន្តែបើទោះបីជាច្បាប់ស្តីពីវិនិយោគឆ្នាំ ១៩៩៤ បានបញ្ញត្តិធានាមិនធ្វើជាតិតូបនីយកម្មលើទ្រព្យសម្បត្តិអ្នកវិនិយោគក៏ដោយ ក៏ជាក់ស្តែងសញ្ញាណនៃពាក្យ *ជាតូបនីយកម្ម*និងយន្តការ

[1] មាត្រា ៩នៃច្បាប់ស្តីពីវិនិយោគឆ្នាំ១៩៩៤ ដែលមិនត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគ បានធ្វើការកំនត់ច្បាស់ថា ***រាជរដ្ឋាភិបាលកម្ពុជា នឹងមិនធ្វើជាតូបនីយកម្ម ដែលនាំឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។***

[2] សូមអាន *សទ្ទានុក្រមបារាំង ខ្មែរ នៃពាក្យច្បាប់* បោះពុម្ពផ្សាយលើកទី២ ដោយសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមការឧបត្ថម្ភពីផ្នែកសហប្រតិបត្តិការសកម្មភាពវប្បធម៌របស់ស្ថានទូតបារាំងឆ្នាំ ២០០៥ ទំព័រ ១៩៥។

របស់វាពុំត្រូវបានបញ្ញត្តិឲ្យច្បាស់លាស់នៅក្នុងច្បាប់ទាំងឡាយ របស់ព្រះរាជាណាចក្រកម្ពុជាយើងនោះឡើយ។ ហេតុនេះចេញអំពីមាត្រា ៩ នៃច្បាប់ស្តីពីវិនិយោគនេះ ចំណោទជាច្រើនដែលពិបាករកចម្លើយអាចនឹងចោទឡើង ដូចជាថាតើរាល់ការដកហូតទាំងអស់តាមផ្លូវច្បាប់នូវទ្រព្យសម្បត្តិរបស់អ្នកវិនិយោគដោយរាជរដ្ឋាភិបាលកម្ពុជា សុទ្ធតែត្រូវចាត់ទុកជាអំពើនៃជាតិតូបនីយកម្មដែលនឹងត្រូវហាមឃាត់នេះ ឬយ៉ាងណា? ទោះបីជាធ្វើលើចលនទ្រព្យរបស់អ្នកវិនិយោគ ឬលើអចលនទ្រព្យរបស់ពួកគេក៏ដោយ? ចុះបើជាការពិន័យលើអ្នកវិនិយោគវិញ? ឬមួយក៏ការដកហូតក្រោមទម្រង់ជាទណ្ឌកម្មរបស់រដ្ឋចំពោះអ្នកវិនិយោគវិញពុំចាត់ទុកជា *ជាតិតូបនីយកម្ម*នៅក្នុងន័យនេះទេឬយ៉ាងណា? តើពិតជាគ្មានលក្ខខណ្ឌណាមួយសម្រាប់ជាអញ្ញត្រកម្មដែលអនុញ្ញាតឲ្យរដ្ឋអាចធ្វើជាតូបនីយកម្មនេះបានទេឬ? ចុះបើមានអំពើនៃជាតិតូបនីយកម្មនេះកើតវិញ តើនឹងមានយន្តការអ្វីដើម្បីសម្រេចនូវកិច្ចធានាតាមមាត្រា ៩ នេះបាន? ហើយនឹងសំនួរដ៏សំខាន់ចុងក្រោយអាចនឹងចោទសួរថាតើការដកហូតកម្មសិទ្ធិឯកជននៃអ្នកវិនិយោគ ក្រោមទម្រង់ជាអស្សាមិករណ៍ដែលច្បាប់អនុញ្ញាត អាចនឹងត្រូវចាត់បញ្ចូលជា ជាតិតូបនីយកម្មដែលច្បាប់វិនិយោគហាមឃាត់នេះបានឬទេ?

## ២. បញ្ហានៃការធានាមិនធ្វើអស្សាមិករណ៍

ដើម្បីអនុវត្តឲ្យបានតាមបញ្ញត្តិនៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់មាត្រា ៤៤ កថាខណ្ឌទី៣ ដែលចែងថា *ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុកហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌* ទើបច្បាប់ស្តីពីអស្សាមិករណ៍ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ក្នុងគោលដៅកំណត់ឲ្យបានច្បាស់លាស់អំពីគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និងសំណងឲ្យបានសមរម្យ និងយុត្តិធម៌សម្រាប់គម្រោងស្ថាបនា ស្តារ និងគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនៅកម្ពុជា។ យោងតាមមាត្រា៣ នៃច្បាប់នេះលើកលែងតែមានកិច្ចព្រមព្រៀង ឬអនុស្សារណៈស្តីពីការគាំពារវិនិយោគរវាងរដ្ឋាភិបាលកម្ពុជា និងប្រទេសជាដៃគូណាមួយអំពីអស្សាមិករណ៍នេះគ្រប់បញ្ហានៃអស្សាមិករណ៍នៅក្នុងវិស័យវិនិយោគគឺត្រូវស្ថិតនៅក្រោមអនុភាពនៃច្បាប់នេះ។

សម្រាប់និយមន័យវិញ *អស្សាមិករណ៍សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈរួមមាន ដី សំណង់ និងដំណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើជាប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និងយុត្តិ*

*ធម៌*[3]។ ទាក់ទងនឹងបញ្ហាអស្សាមិករណ៍នៅក្នុងវិស័យវិនិយោគនេះ សំនួរអាចចោទសួរថា កាលបើអស្សាមិករណ៍ត្រូវធ្វើលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សណាមួយរបស់អ្នកវិនិយោគនោះ យន្តការនៃការដកហូតនេះនឹងត្រូវអនុវត្តតាមច្បាប់ស្តីពីអស្សាមិករណ៍[4]។

ប៉ុន្តែជាក់ស្តែងសញ្ញាណនៃអស្សាមិករណ៍ក្នុងវិស័យវិនិយោគពុំត្រូវបានប្រទះឃើញទាល់តែសោះនៅក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ ឈរលើនិយមន័យនៃអស្សាមិករណ៍ដែលច្បាប់ស្តីពីអស្សាមិករណ៍កំណត់ យើងអាចចោទជាសំនួរថា តើអស្សាមិករណ៍នេះពិតជាមិនអាចបញ្ចូលទៅក្នុងសញ្ញាណនៃជាតូបនីយកម្មក្នុងវិស័យវិនិយោគបានទេឬ កាលបើអស្សាមិករណ៍នេះក៏ពិតជាទម្រង់មួយនៃការដកហូតទ្រព្យសម្បត្តិឯកជនរបស់អ្នកវិនិយោគ មកជាសម្បត្តិសាធារណៈតាមផ្លូវច្បាប់ផងដែរនោះ?[5] បើចម្លើយថា ពិតជាអាចបញ្ចូលគ្នាបាន មែននោះនឹងបង្កើតឲ្យមានជម្លោះគ្នារវាងយន្តការបើកផ្លូវសម្រាប់ធ្វើអស្សាមិករណ៍ដែលបញ្ញត្តិដោយច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០ និងការហាមឃាត់ចំពោះការធ្វើជាតូបនីយកម្មដោយច្បាប់ស្តីពីវិនិយោគឆ្នាំ ១៩៩៤ តាមគោលការណ៍ច្បាប់ថ្មីលុបលើច្បាប់ចាស់ដែលនឹងផ្ទុយ នៅក្នុងករណីអស្សាមិករណ៍នេះ ឬនៅតែត្រូវអនុវត្តច្បាប់ស្តីពីវិនិយោគឆ្នាំ១៩៩៤ ដដែល ដោយឈរលើគោលការណ៍ថាច្បាប់ស្តីពីវិនិយោគជាច្បាប់ពិសេសនៃអស្សាមិករណ៍ ដែលត្រូវលុបលើច្បាប់ស្តីពីអស្សាមិករណ៍ ក្នុងករណីវិនិយោគនេះទៅវិញ? ចម្លើយពិតប្រាកដណាមួយនឹងត្រូវបានបកស្រាយ តែក្នុងករណីដែលជម្លោះក្នុងបញ្ហាអស្សាមិករណ៍នេះកើតមាន ហើយចម្លើយនឹងយកជាការបានតែកាលណាបើស្ថាប័នមានសមត្ថកិច្ចដូចជាតុលាការ ឬក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកបកស្រាយបញ្ហានេះប៉ុណ្ណោះ។

### ៣. ការធានាកម្មសិទ្ធិបញ្ញា

ការធានាកម្មសិទ្ធិបញ្ញា សំដៅដល់ការធានាថានឹងមានយន្តការការពារឲ្យដល់ស្នាដៃបង្កើតថ្មីទាំងឡាយរួមមានដូចជាស្នាដៃនិពន្ធ ស្នាដៃតក្កកម្ម ឬសិទ្ធិលើម៉ាក ពាណិជ្ជនាមជាដើម ប្រឆាំងទល់នឹងការលួចចម្លងដោយខុសច្បាប់ដែលហៅថា អំពើក្លែងបន្លំ ។ ជាទូទៅសកម្មភាពវិនិយោគរមែងផ្តោតទៅលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យា ដែលថ្វីត្បិតតែជាវិស័យមួយត្រូវចំណាយទុនវិនិយោគខ្ពស់ ប៉ុន្តែក៏កាក់កបនូវផលចំនេញ នឹងមានស្ថេរភាពយូរអង្វែងផងដែរ។ ទោះជាយ៉ាងនេះក្តី អត្ថប្រយោជន៍ទាំងនេះនឹងអាចធ្លាក់មកដល់ដៃអ្នកវិនិយោគបាន តែល្គឹកណាដែលកម្មសិទ្ធិបញ្ញាដែលបង្កើតនោះត្រូវ

[3] មាត្រា ៤ នៃច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០

[4] ដូចដែលមានចែងត្រង់មាត្រា ៣ នៃច្បាប់ស្តីពីអស្សាមិករណ៍

[5] ត្រង់ចំណុចនេះ សូមអានទៅផ្នែកខាងក្រោយអំពី ការមិនធ្វើជាតូបនីយកម្មវិនិយោគ

បានធានា និងការពារដោយច្បាប់ ប្រឆាំងនឹងរាល់រូបភាពនៃការលួចចម្លងស្នាដៃទាំងឡាយនោះរបស់អ្នកវិនិយោគ។

ដោយឡែកចំពោះកិច្ចការពារនេះ កម្ពុជាបានបង្កើតនូវក្របខណ្ឌច្បាប់មួយចំនួន ក្នុងពេលដែលខ្លួនចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ក្រោមជំនួយ និងកិច្ចសហការពីអង្គការអន្តរជាតិនានា ដូចជាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ធនាគារពិភពលោក ក៏ដូចជាធនាគារអភិវឌ្ឍន៍អាស៊ីជាដើម ក្របខណ្ឌច្បាប់កម្មសិទ្ធិបញ្ញារបស់កម្ពុជានេះត្រូវបានបង្កើតឡើងក្នុងគោលដៅធានា និងទាក់ទាញអ្នកវិនិយោគជាធំ។ ច្បាប់ទាំងនោះរួមមានដូចជា: ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធប្រហាក់ប្រហែល ។ ក៏ប៉ុន្តែចំណោទនៃប្រសិទ្ធភាពអនុវត្តន៍នៃបណ្តាច្បាប់ថ្មីៗទាំងនេះនៅតែមាននៅឡើយ។

### ៤. ការធានាចរាចររូបិយបណ្ណ

ដោយអនុលោមទៅតាមច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ព្រមទាំងបទបញ្ញត្តិទាំងឡាយដែលបានកំណត់ និងប្រកាសផ្សាយដោយធនាគារជាតិកម្ពុជា រាជរដ្ឋាភិបាលអនុញ្ញាតដល់អ្នកវិនិយោគមានសិទ្ធិទិញរូបិយបណ្ណបរទេសតាមរយៈប្រព័ន្ធធនាគារ សម្រាប់បង្វិលទៅបរទេសវិញដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន។

ការទូទាត់រួមមានៈ

- ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេសទាំងដើម ទាំងការប្រាក់នូវប្រាក់ចងការ
- ការទូទាត់ចំណាយសួយសារ និងថ្លៃសេវាគ្រប់គ្រង។
- ការផ្ទេរប្រាក់ចំណេញ
- ការបង្វិលដើមទុនវិនិយោគទៅក្រៅប្រទេសវិញ [6]។

## កថាខណ្ឌទី២ ការលើកទឹកចិត្តចំពោះការវិនិយោគ

កាលពីមុន យោងតាមច្បាប់ចាស់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ការធ្វើវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានលើកទឹកចិត្ត ដោយក្នុងនោះរាជរដ្ឋាភិបាលបានខិតខំធ្វើការលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីជំរុញឲ្យមានការវិនិយោគទៅលើវិស័យសំខាន់ៗដែលរួមមាន[7]៖

- ឧស្សាហកម្មនាំមុខ ឬឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់

[6] មាត្រា ១១ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០០៣

[7] មាត្រា ១២ ច្បាប់ស្តីពីវិនិយោគ ចុះថ្ងៃទី០៥ ខែ សីហា ឆ្នាំ១៩៩៤

- ការបង្កើតការងារ
- ការបង្កើនការនាំចេញ
- ឧស្សាហកម្មទេសចរណ៍
- ការផលិតទំនិញកសិឧស្សាហកម្ម និងឧស្សាហកម្មកែច្នៃ
- ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផលិតថាមពល
- អភិវឌ្ឍន៍ខេត្ត និងជនបទ
- ការការពារបរិស្ថាន
- ការវិនិយោគក្នុងតំបន់អភិវឌ្ឍន៍ពិសេសដែលនឹងត្រូវបង្កើតឡើងដោយច្បាប់

តែក្រោយមកមានការធ្វើវិសោធនកម្មដោយការលើកទឹកចិត្តចំពោះអ្នកវិនិយោគ ដោយរាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ [8]។ នៅពេលដែលបានចុះបញ្ជីសុំការលើកទឹកចិត្តចំពោះការវិនិយោគរួចមក គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងទទួលបានការលើកទឹកចិត្តចំពោះការលើកលែងពន្ធលើប្រាក់ចំនេញ ការរំលោះពិសេស ការលើកលែងពន្ធគយ រួមទាំងការធានាមួយចំនួនផងដែរ។

### ១. ការលើកលែងពន្ធលើប្រាក់ចំនេញ

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបានការលើកលែងពន្ធលើប្រាក់ចំនេញដែលមានកំណត់ក្នុងច្បាប់ស្តីពីសារពើពន្ធ ដោយទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំនេញ។ រយៈពេលអាទិភាពនឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ។ រយៈពេលគន្លឹះជាអតិបរមា គឺជាឆ្នាំទី១ ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំនេញ ឬរយៈពេល៣ឆ្នាំបន្ទាប់ពីគម្រោងវិនិយោគនោះបានទទួលប្រាក់ចំណូលដំបូងរបស់ខ្លួនដោយជ្រើសយកជម្រើសណាមួយដែលឆាប់ជាង [9]។

#### ១.១ ការរំលោះពិសេស

នៅពេលមានការជ្រើសរើស លើពន្ធប្រាក់ចំនេញ ដែលធ្វើជាលាយលក្ខណ៍អក្សរ នោះបានសេចក្តីថាជាការជ្រើសរើសដោយបដិសេធនូវការរំលោះពិសេសផ្នែកសារពើពន្ធផ្សេងៗ ដែលធ្វើឲ្យអ្នកវិនិយោគ គ្មានសិទ្ធិក្នុងការទាមទាររំលោះពិសេសផ្នែកវិនិយោគ ដែលអនុវត្តសម្រាប់អ្នកវិនិយោគ តាមច្បាប់ស្តីពីសារពើពន្ធទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ។ ផ្ទុយទៅវិញ

[8] មាត្រា ១២ថ្មី ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣

[9] មាត្រា ១៤ថ្មី វាក្យខណ្ឌ១ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ខែមីនាឆ្នាំ២០០៣

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមិនទទួលបានការលើកលែងពន្ធ គឺមានសិទ្ធិធ្វើការទាមទារការរំលោះពិសេសបាន។

### ១.២ ការលើកលែងពន្ធគយ

ការលើកទឹកចិត្តចំពោះការវិនិយោគ បានជួយដល់ការលើកលែងពន្ធគយផងដែរ ចំពោះអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបម្រើទីផ្សារក្នុងស្រុកមានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខារផលិតកម្មសម្ភារៈសាងសង់បម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

ក្រៅពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឲ្យការនាំចេញដែលជ្រើសរើសឬបានជ្រើសរើសយកយន្តការភណ្ឌាគារផលិតកម្មក្រោមការគ្រប់គ្រងរបស់គយ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឲ្យការនាំចេញដទៃទៀត មានសិទ្ធិនាំចូលដោយឲ្យរួចពន្ធនូវគ្រឿងសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ។ លើសពីនេះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រមានសិទ្ធិនាំចូលដោយរួចពន្ធ នូវគ្រឿងសម្ភារៈបរិក្ខារផលិតកម្មសម្ភារៈសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យផងដែរ។

### ១.៣ ដែនកំណត់

តាមមាត្រា ១៨ថ្មី វាក្យខណ្ឌ៣ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវជាប់ពន្ធលើប្រាក់ចំណេញ។

អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ត្រូវបានកំណត់ចំនួន ៩ភាគរយ ចំពោះសហគ្រាសវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់រយៈពេលអន្តរកាល៥ឆ្នាំ។ ក្រៅពីអត្រាពន្ធខាងលើនេះ នៅមានពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភដែលបានកំណត់ដូចតទៅ៖

- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ២០ភាគរយនៃទឹកប្រាក់បែងចែកចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធនៃគម្រោងវិនិយោគដែលត្រូវបង់ពន្ធតាមអត្រា ០ភាគរយ ឬការបែងចែកដទៃទៀត។

- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ១១ភាគ ៨១ នៃទឹកប្រាក់ត្រូវបែងចែកចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធនៃគម្រោងវិនិយោគដែលត្រូវបង់ពន្ធតាមអត្រា ៩ភាគរយ។

## ២. តំបន់សេដ្ឋកិច្ចពិសេស

អត្ថប្រយោជន៍ទាំងឡាយដែលច្បាប់កម្ពុជាសម្រេចផ្តល់ដល់អ្នកវិនិយោគអាចប្រែប្រួលផងដែរទៅតាមតំបន់ដែលអ្នកវិនិយោគនោះជ្រើសរើសសម្រាប់សកម្មភាពវិនិយោគរបស់ពួកគេ។ នៅក្នុងន័យនេះ តំបន់វិនិយោគនៅកម្ពុជាអាចត្រូវបានបែងចែកជាពីរគឺៈ តំបន់វិនិយោគធម្មតា និងតំបន់វិនិយោគពិសេសដែលមានឈ្មោះថា តំបន់សេដ្ឋកិច្ចពិសេស ។ ក្រៅអំពីតំបន់ដែលវិធានច្បាប់ហាមប្រាមសម្រាប់សកម្មភាពវិនិយោគ[10] តំបន់វិនិយោគធម្មតាសំដៅទៅដល់តំបន់វិនិយោគទាំងឡាយណាដែលពុំបានស្ថិតនៅក្នុងលក្ខណៈវិនិច្ឆ័យជាតំបន់សេដ្ឋកិច្ចពិសេស។ ដូចនេះ ចំណោទគប្បីស្ថិតនៅត្រង់ថាៈ តើដូចម្តេចទៅដែលហៅថាតំបន់សេដ្ឋកិច្ចពិសេស? តើសកម្មភាពវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទទួលបាននូវអត្ថប្រយោជន៍ខុសគ្នាម្តេចខ្លះ អំពីសកម្មភាពនៅក្នុងតំបន់វិនិយោគធម្មតា? ហេតុអ្វីចាំបាច់មានតំបន់សេដ្ឋកិច្ចពិសេសនេះ សម្រាប់វិស័យវិនិយោគនៅកម្ពុជា?

តំបន់សេដ្ឋកិច្ចពិសេសនេះ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ *១៤៨ អនក្រ.បក* ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។ តាមនិយមន័យដែលកំនត់ដោយមាត្រា ២នៃអនុក្រឹត្យ តំបន់សេដ្ឋកិច្ចប្រភេទនេះ ត្រូវបានចាត់ទុកដូចជា **មជ្ឈមណ្ឌលពិសេសសំរាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ដែលប្រមូលផ្តុំនូវសកម្មភាពឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀត ហើយ**

[10] យោងតាមមាត្រា ១២ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤ ចែងថាៈ *រាល់បុគ្គល ឬស្ថាប័នឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈត្រូវហាមឃាត់មិនឲ្យសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈដូចតទៅៈ*

- *ទីបំរុងទឹក និងទំនប់ទឹក*
- *ទីបំរុងជីករ៉ែ និងតំបន់ព្រៃឈើ*
- *រមណីយដ្ឋានបុរាណវិទ្យា និងតំបន់អភិវឌ្ឍន៍*
- *ដីបំរុងទុកសម្រាប់ផ្លូវ បម្រុងសម្រាប់ចំណីផ្លូវ និងដីបម្រុងទុកសម្រាប់ផ្លូវរថភ្លើង និងអាកាសយានដ្ឋាន*
- *ទន្លេ សមុទ្រ ព្រែក ស្ទឹង ព្រមទាំងឆ្នេរច្រាំង*
- *ជាទូទៅនៅលើដីទាំងឡាយណាដែលបញ្ញត្តិច្បាប់កំណត់មិនឲ្យសាងសង់។*

*លក្ខខណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះលក្ខខណ្ឌសំណង់ ឬតាំងទីលំនៅធុនស្រាល បណ្តោះអាសន្ន អនុញ្ញាតបានដោយអនុក្រឹត្យ។*

**អាចមានតំបន់ឧស្សាហកម្មទូទៅ និងតំបន់ផលិតកែច្នៃនាំចេញ**[11]។ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនីមួយៗត្រូវមានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាននិងមណ្ឌលទេសចរណ៍[12]។ និយាយម្យ៉ាងទៀត តំបន់សេដ្ឋកិច្ចពិសេសនេះ គឺជាមជ្ឈមណ្ឌលប្រមូលផ្តុំរួមមួយនូវសកម្មភាពឧស្សាហកម្ម (រួមមានៈ រោងចក្រ ឬសហគ្រាសនានាសម្រាប់ការផលិតទំនិញ)សកម្មភាពពាណិជ្ជកម្ម (ពោលគឺជាទីផ្សារនៃផលិតផលដែលផលិតបានផងដែរ) និងសកម្មភាពរដ្ឋបាលផងដែរ(សំដៅដល់អង្គភាពរដ្ឋបាលរបស់រដ្ឋ ដែលជាច្រកចេញចូលតែមួយសម្រាប់សម្រួលរាល់នីតិវិធីរដ្ឋបាលនានា) ដោយមានការបំពាក់នូវរាល់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដើម្បីសម្រាប់បម្រើឲ្យសកម្មភាពទាំងនោះផងដែរ។

នៅក្នុងគោលដៅបង្កើននូវបរិយាកាសវិនិយោគ ដែលអំណោយដល់ការធ្វើឲ្យកាន់តែប្រសើរនូវផលិតភាពក្នុងការផលិតទំនិញ ការប្រជែងឈ្នះ កំណើនសេដ្ឋកិច្ច ជម្រុញការនាំចេញ ដោះស្រាយការងារជូនប្រជាជនដើម្បីកាត់បន្ថយភាពក្រីក្រ ព្រមទាំងដើម្បីកំណត់អំពីនីតិវិធី និងបទប្បញ្ញត្តិទាំងឡាយទាក់ទងនឹងការបង្កើត ការគ្រប់គ្រង សម្របសម្រួលរាល់សកម្មភាពវិនិយោគ និងជម្រុញលើកទឹកចិត្តដល់ការវិនិយោគរបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា [13] តំបន់សេដ្ឋកិច្ចពិសេសចំនួន២២ត្រូវបានបង្កើតរួចមកហើយនៅត្រឹមដើមឆ្នាំ ២០០៩ [14] នេះ។ ម្យ៉ាងទៀត ស្ទើរតែគ្រប់តំបន់សេដ្ឋកិច្ចពិសេសដែលត្រូវបានបង្កើតឡើងទាំងអស់ សុទ្ធសឹងស្ថិតនៅតាមបណ្តោយព្រំដែនថៃ និងវៀតណាម និងនៅតាមទីតាំងក្បែរកំពង់ផែជាច្រកដឹកជញ្ជូននានា ជាហេតុនាំឲ្យតំបន់នេះទទួលបាននូវគុណប្រយោជន៍ពិសេសជាច្រើន។ ក្រៅអំពីគុណប្រយោជន៍នៅក្នុងការទាក់ទាញដ៏ប្រសើរនូវអ្នកវិនិយោគអំពីបណ្តាប្រទេសដែលនៅជាប់ព្រំប្រទល់ទាំងពីរ (ថៃ និងវៀតណាម) ការដាក់ទីតាំងនៅជាប់ព្រំដែនក៏បានផ្តល់ដល់តំបន់សេដ្ឋកិច្ចពិសេសនេះ នូវប្រភពថាមពលអគ្គិសនីដែលមានតម្លៃថោកពីប្រទេសជិតខាងនោះផង និងភាពងាយស្រួលក្នុងការនាំចេញទៅទីផ្សារនៃប្រទេសទាំងនោះផងទៀត ជាពិសេសនៅក្នុងកាលៈទេសៈដែលប្រទេសកម្ពុជាខ្លួនឯងនៅពុំទាន់អាចផ្គត់ផ្គង់ថាមពលអគ្គិសនីបានគ្រប់គ្រាន់នៅឡើយទេសម្រាប់សកម្មភាពបែបនេះផង ហើយទីផ្សារកម្ពុជាក៏នៅតូចចង្អៀតចំពោះរាល់ទំនិញដែលផលិតបាន ឬក៏នាំចូលមកនោះផងទៀត។

---

[11] មាត្រា២ នៃអនុក្រឹត្យលេខ១៤៨ ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស

[12] សូមមើលមាត្រា២ នៃអនុក្រឹត្យលេខ១៤៨

[13] មាត្រា១ ចំណុច ១.១ នៃអនុក្រឹត្យលេខ១៤៨ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

[14] មើលគេហទំព័រ http://investincambodia.com/economiczone/sezs.htm

ជាចុងក្រោយ បន្ទាប់ពីតំបន់សេដ្ឋកិច្ចពិសេសត្រូវបានបង្កើតឡើង [15] រាល់សកម្មភាពវិនិយោគនៅក្នុងតំបន់នេះនឹងទទួលបាននូវអត្ថប្រយោជន៍ជាការលើកទឹកចិត្តជាច្រើនពីរដ្ឋ។ បន្ថែមពីលើការលើកទឹកចិត្តទាំងឡាយដែលផ្តល់ដោយច្បាប់ស្តីពីវិនិយោគ ចំពោះគ្រប់គម្រោងវិនិយោគទូទៅទាំងអស់នៅកម្ពុជា សកម្មភាពវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស នឹងទទួលបានការលើកទឹកចិត្តចំពោះអាករលើតម្លៃបន្ថែមតាមអត្រាសូន្យភាគរយ។ លើសពីនេះទៅទៀត សម្រាប់អ្នកអភិវឌ្ឍន៍តំបន់ មានការលើកទឹកចិត្តដូចជាអាចរូចពន្ធចំពោះរាល់គ្រឿងចក្រ សម្ភារៈបរិក្ខាដែលបម្រើឲ្យសកម្មភាពសាងសង់ផ្លូវនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ក៏ដូចជាផ្លូវតភ្ជាប់មកតំបន់សេដ្ឋកិច្ចពិសេសនេះ រួមទាំងការលើកលែងពន្ធបណ្តោះអាសន្ន សម្រាប់បណ្តាមធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រនានាផងដែរ។ អ្នកអភិវឌ្ឍន៍តំបន់ដែលទទួលបានដីសម្បទានពីរដ្ឋសម្រាប់អភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនេះ ក៏នៅមានសិទ្ធិស្របច្បាប់ដែលផ្តល់ឲ្យដោយអនុក្រឹត្យនេះ ក្នុងការជួយបន្តទៅអ្នកវិនិយោគក្នុងតំបន់ដទៃទៀតផងដែរ។

### ២.១ ការលើកទឹកចិត្តវិនិយោគសម្រាប់តំបន់សេដ្ឋកិច្ចពិសេស

តំបន់សេដ្ឋកិច្ចពិសេស មានការលើកទឹកចិត្តចំពោះសកម្មភាពវិនិយោគ ដោយនៅក្នុងអនុក្រឹត្យស្តីពីការបង្កើតតំបន់នេះ បានចែងពីនីតិវិធីនៃការលើកទឹកចិត្ត ការលើកទឹកចិត្តផ្នែកសារពើពន្ធ និងការលើកទឹកចិត្តដទៃទៀត។

#### ២.១.១ នីតិវិធីនៃការលើកទឹកចិត្ត

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាពិនិត្យ និងផ្តល់ការលើកទឹកចិត្តដល់គ្រប់តំបន់សេដ្ឋកិច្ចពិសេសទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា:

- សំណើសុំនាំចូលឧបករណ៍សម្ភារៈបរិក្ខារ សម្ភារៈសំណង់ដោយរួចពន្ធសម្រាប់ការងារសាងសង់តំបន់របស់អ្នកអភិវឌ្ឍនិតំបន់

[15] ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនេះ ត្រូវគោរពតាមឲ្យបានជាចាំបាច់នូវលក្ខខណ្ឌ និងនីតិវិធីដែលកំណត់ដោយច្បាប់។ ត្រូវមានទំហំដីចាប់ពី ៥០ហិចតាឡើងទៅ មានរបងព័ទ្ធជុំវិញ មានអាគារការិយាល័យចាត់ចែងការងារ ការិយាល័យរដ្ឋបាល មានប្រព័ន្ធទឹកស្អាត អគ្គិសនី បណ្តាញប្រៃសណីយ៍ នឹងទូរគមនាគមន៍ ប្រព័ន្ធសុវត្ថិភាព ប្រព័ន្ធបង្ហូរទឹកសំអុយ ប្រព័ន្ធប្រព្រឹត្តិកម្មសម្អាតកាកសំណល់ និងវិធានការពារបរិស្ថាននានាបានយ៉ាងត្រឹមត្រូវ តំបន់សេដ្ឋកិច្ចពិសេសត្រូវតែបង្កើតឡើងនៅក្នុងតំបន់សមស្រប និងប្រកបដោយយុទ្ធសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាតាមការសម្រេចរបស់រាជរដ្ឋាភិបាល ប៉ុន្តែក្រោមគំនិតផ្តួចផ្តើមរបស់ឯកជន ឬរបស់រដ្ឋ ឬក៏របស់រដ្ឋចម្រុះឯកជន (មាត្រា៣ ចំនុច៣.១ នៃអនុក្រឹត្យលេខ១៤៨)។ ត្រូវបានចាត់ទុកដូចជាការវិនិយោគមួយដែរនោះ គម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសត្រូវតែស្នើសុំមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា) ដើម្បីទទួលបានគុណភាពជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ស្របតាមច្បាប់ស្តីពីវិនិយោគរបស់កម្ពុជា ប៉ុន្តែស្ថិតក្រោមនីតិវិធីពិសេសដូចមានចែងក្នុងអនុក្រឹត្យទៅវិញ (សូមអានមាត្រា៣ ចំនុច ៣.២ នៃអនុក្រឹត្យលេខ១៤៨)។

ត្រូវដាក់ជូនគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាដើម្បីពិនិត្យ និងសម្រេច។

- ការលើកទឹកចិត្តលើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសំណង់ ធាតុចូលផលិតកម្មត្រូវតែសម្រេចផ្តល់ជូនដល់អ្នកវិនិយោគក្នុងតំបន់តាមសំណូមពរ និងគោលការណ៍នៃច្បាប់ដោយសាមុីអ្នកវិនិយោគក្នុងតំបន់នោះត្រូវរៀបចំបញ្ជីសម្ភារៈបរិក្ខារ ផលិតកម្ម សម្ភារៈសំណង់ និងធាតុចូលផលិតកម្មដែលត្រូវសុំនាំចូលទាំងនោះ ដាក់ជូនរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសពិនិត្យដែលនឹងត្រូវសម្រេចផ្តល់ជូននៅនឹងកន្លែង ហើយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសគ្រាន់តែរាយការណ៍ជូនមកគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងស្ថាប័នគ្រប់គ្រងដើម្បីជ្រាបជាដំណឹងប៉ុណ្ណោះ។
- សិទ្ធិដែលត្រូវបានទទួលការលើកទឹកចិត្តផ្នែកសារពើពន្ធនឹងសម្រេចជូនអ្នកវិនិយោគក្នុងតំបន់នៅក្នុងវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ដែលនឹងត្រូវចេញជូនអ្នកវិនិយោគក្នុងតំបន់ស្របតាមច្បាប់ និងអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

### ២.១.២ ការលើកទឹកចិត្តផ្នែកសារពើពន្ធ

អ្នកអភិវឌ្ឍនិតំបន់ ត្រូវទទួលបាននូវការលើកទឹកចិត្តទាំងឡាយសម្រាប់សកម្មភាពវិនិយោគដូចតទៅ៖

- ពន្ធលើប្រាក់ចំនេញ រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ត្រូវបានផ្តល់ជូនសម្រាប់រយៈពេលអតិបរមា ៩ឆ្នាំ។
- ពន្ធនាំចូល និងអាករផ្សេងៗការនាំចូលសម្ភារៈបិរក្ខារ សម្ភារៈសាងសង់ ដែលត្រូវប្រើប្រាស់ក្នុងតំបន់សម្រាប់បម្រើឲ្យការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ ត្រូវបានអនុញ្ញាតដោយពន្ធនាំចូល និងអាករផ្សេងៗជាបន្ទុករបស់រដ្ឋ។

អ្នកវិនិយោគក្នុងតំបន់ ដែលទទួលបាននូវការលើកទឹកចិត្តចំពោះអាករលើតម្លៃបន្ថែមលើអត្រា 0 ភាគរយ ត្រូវបានធ្វើការកត់ត្រាទុកនូវប្រាក់ពន្ធដែលបានលើកលែងនេះ សម្រាប់រាល់ករណីនាំចូលមួយលើកៗរបស់អ្នកវិនិយោគក្នុងតំបន់ ហើយតួលេខកត់ត្រាប្រាក់ពន្ធនេះ នឹងត្រូវលុបចោល ប្រសិនបើធាតុចេញផលិតកម្មត្រូវបាននាំចេញទៅវិញ។ ក្នុងករណីដែលធាតុចេញផលិតកម្មបានបង្វិលនាំចូលទីផ្សារក្នុងស្រុក អ្នកវិនិយោគក្នុងតំបន់ត្រូវបង់សងវិញនូវអាករលើតម្លៃបន្ថែមនេះវិញតាមចំនួនទឹកប្រាក់ ដែលបានកត់ត្រាប្រៀបធៀបទៅនឹងបរិមាណដែលបាននាំចេញ។

### ២.១.៣ ការលើកទឹកចិត្តដទៃទៀត

អ្នកវិនិយោគក្នុងតំបន់ ត្រូវទទួលបាននូវការនាំចូលដោយរួចពន្ធចំពោះគ្រឿងចក្រ សម្ភារៈបរិក្ខារសម្រាប់ការសាងសង់ផ្លូវ ដែលត្រូវបានតភ្ជាប់ពីទីប្រជុំជន ទៅតំបន់ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសម្រាប់សេវាសាធារណៈផ្សេងៗទៀតដើម្បីផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍របស់តំបន់ផ្ទាល់។

អ្នកវិនិយោគក្នុងតំបន់អាចសុំនាំចូលតាមរូបភាពរួចពន្ធបណ្តោះអាសន្ន នូវបណ្តាមធ្យោបាយដឹកជញ្ជូនគ្រឿងចក្រ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងដំណើរការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។

ការនាំចូលទាំងអស់របស់អ្នកអភិវឌ្ឍនិតំបន់និងអ្នកវិនិយោគក្នុងតំបន់ត្រូវអនុវត្តទៅតាមបទបញ្ញត្តិពាក់ព័ន្ធស្តីពីអធិការកិច្ចទំនិញមុនពេលផ្ទុក។

អ្នកអភិវឌ្ឍនិតំបន់ អ្នកវិនិយោគក្នុងតំបន់ និយោជិតបរទេស មានសិទ្ធិផ្ទេរទៅក្រៅប្រទេសនូវរាល់ប្រាក់ចំណូលពីការវិនិយោគ ប្រាក់បៀវត្ស ដែលទទួលបាននៅក្នុងតំបន់តាមរយៈធនាគារក្រោយពេលបានបង់ពន្ធរួច។

ក្រៅពីការលើកទឹកចិត្តផ្នែកសារពើពន្ធ អ្នកអភិវឌ្ឍនិតំបន់ អ្នកវិនិយោគក្នុងតំបន់មានសិទ្ធិទទួលបាននូវការធានាវិនិយោគផងដែរ។ អ្នកអភិវឌ្ឍនិតំបន់ អាចទទួលបាននូវដីសម្បទានសម្រាប់បង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅតាមតំបន់ជាប់ព្រំដែន ឬតំបន់ដាច់ស្រយាលស្របតាមច្បាប់ភូមិបាលហើយអាចជួលបន្តទៅឲ្យអ្នកវិនិយោគក្នុងតំបន់។